# ការឆ្លងទន្លេនៅភូមិស្នាយពល

ការកើតកូន ខ្មែរយើងតែងហៅថាឆ្លងទន្លេ ព្រោះគេប្រដូចឧបសគ្គនៃការកើតកូន ទៅនឹងឧបសគ្គដែលអាចកើតឡើងក្នុងការហែលទឹក ឬ ជិះទូកឆ្លងទន្លេដែរគឺ បើឆ្លងមិនរួច ឬ មិនដល់ច្រាំងអាចត្រូវលង់ទឹកស្លាប់ ។ ការឆ្លងទន្លេក៏ដូច្នោះដែរ ទាំងកូនទាំងម្តាយ អាចទទួលគ្រោះថ្នាក់ដល់ជីវិត ។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ នៅក្នុងភូមិស្នាយពល មានមន្ត្រីសុខាភិបាលតែម្នាក់គត់មានឋានៈត្រឹមគិលានុប្បដ្ឋាកគ្មានធ្មបនៅប្រចាំទេ[15] ។ អ្នកស្រុកភាគច្រើននៅពេលមាន ជម្ងឺតែងទៅរកគ្រូបុរាណប្រើថ្នាំខ្មែរជាជាងទៅរកគ្រូពេទ្យ ។ នៅពេលស្ត្រីកំពុងឆ្លងទន្លេគឺទារកកំពុងចេញពីផ្ទៃម្តាយ មនុស្សប្រុសៗ គេមិនអនុញ្ញាតឲ្យនៅក្នុងបន្ទប់ជាមួយឡើយ ។ បុរសដែលក្លាយជាឪពុកត្រូវរៀបចំគ្រែ ចង្ក្រាន និង ធ្យូងនៅទីជាប់ដោយឡែក ព្រោះនៅពេលដែលទារកចេញមកហើយ ស្ត្រីជាម្តាយត្រូវមកសម្រាកអាំងភ្លើងយកកម្តៅ អស់រយៈពេលបីថ្ងៃទើបឈប់ ។ នៅពេលប្រពន្ធសម្រាកនៅលើគ្រែ បុរសជាប្តី ត្រូវថែទាំមើលភ្លើងធ្យូង ភ្លើងក្នុងចង្ក្រានកុំឲ្យរលត់ ។ ការនេះ ជាការទទួលខុសត្រូវរបស់បុរសជាស្វាមីដែលមិនត្រូវខ្វះបានឡើយ ព្រោះនៅពេលភរិយាឆ្លងទន្លេនេះហើយ ដែលប្តីត្រូវបញ្ជាក់ពីសេចក្តីស្រឡាញ់ចំពោះប្រពន្ធ ឪពុកចំពោះកូន ដែលទើបនឹងកើត និង ចំពោះគ្រួសារទាំងមូលផង ។

នៅពេលឆ្លងទន្លេនេះ យាយម៉បនឹងបំពេញភារកិច្ចរបស់គាត់ដូចជា៖ ផ្សំថ្នាំលាយម្សៅ ឬ លាយរមៀតជាដើម ។ ម្តាយខ្ញុំ គាត់តែងពិសាស្រារ៉ូម (Rhum) ជំនួសស្រាថ្នាំនៅពេលឆ្លងទន្លេម្តងៗ ។ បីថ្ងៃក្រោយមក គេអាចរើចង្ក្រានពីក្រោម

---

[15] Cf. Sorn Samnang, L'évolution de la société cambodgienne entre les deux guerres mondiales (1919-1939), op.cit, p. 396-399.

គ្រែចេញ ដែលខ្មែរយើងហៅថាទម្លាក់ចង្ក្រាន ។ ម្តាយត្រូវនៅបន្តសម្រាកលើគ្រែនេះតទៅទៀត មិនមានកំណត់ពេលឡើយ រហូតទាល់តែមានកម្លាំងពលំគ្រប់គ្រាន់ ។ ក្នុងរយៈពេលនេះ គេត្រូវប្រយ័ត្នប្រយែងយ៉ាងខ្លាំង ព្រោះសសៃនៅខ្ចីអាចឲ្យទាស់ នាំមកនូវជម្ងឺផ្សេងៗ ។

តាមទម្លាប់ខ្មែរយើង កូនកើតមកភ្លាម គេមិនទាន់ប្រញាប់ប្រញាល់ដាក់ឈ្មោះឲ្យកូននោះដូចនៅលោកខាងលិចនោះទេ ។ ប្រហែលជាដូនតាយើងយល់ឃើញថាត្រូវរង់ចាំមើលបន្តិចសិន ព្រោះអត្រាទារកស្លាប់ភ្លាមៗ ឬ ក្នុងអាយុពីមួយអាទិត្យទៅមួយខែ មានកម្រិតខ្ពស់ពេក ទើបគេមិនប្រញាប់រកឈ្មោះដាក់ឲ្យកូននៅពេលភ្លាមៗនោះ ។ ឪពុកខ្លះរង់ចាំពិភាក្សាជាមួយព្រះសង្ឃ លោកតាអាចារ្យ ឬ មេស្រុក មេភូមិ ដើម្បីរកឈ្មោះដាក់ឲ្យកូនឲ្យបានសមរម្យ ។ ការចុះសំបុត្រកំណើតរបស់ទារក ក៏មានលក្ខណៈដូចគ្នានេះដែរគឺ មិនប្រញាប់ប្រញាល់ប៉ុន្មានឡើយ ។ យូរៗទៅ ការចុះសំបុត្រកំណើត ក៏ស្រេចតែលើមន្ត្រីអត្រានុកូលដ្ឋានជាអ្នកសម្រេចថ្ងៃណា ខែណា ដែលសមស្រប ។ ក៏ប៉ុន្តែ ឪពុកម្តាយភាគច្រើន តែងចាំថ្ងៃខែកំណើតរបស់កូន ទៅតាមប្រតិទិនច័ន្ទគតិគឺ គេរាប់ឆ្នាំតាមឈ្មោះសត្វទាំង១២ និង តាមខែដែលយើងហៅថាខែខ្មែរ ដោយមានខ្នើត និង រនោចផង ។ ព្រោះទាំងនេះមានសារសំខាន់ណាស់ សម្រាប់ធ្វើការទស្សន៍ទាយតាមក្បួនហោរាសាស្ត្រអំពីជោគវាសនាអនាគតរបស់កូនម្នាក់ៗ ។

ចំពោះរូបខ្ញុំអ្វីៗដែលមានចុះក្នុងបញ្ជីជាតិរបស់ខ្ញុំ ក៏ខុសស្រឡះពីអ្វីៗដែលឪពុកម្តាយខ្ញុំបាននិយាយប្រាប់ផ្ទាល់មាត់តៗមក ។ ជាធម្មតាឪពុកម្តាយខ្ញុំ តាំងពីពួកយើងជាកូននៅតូចៗ តែងតែបង្រៀនឲ្យយើងស្គាល់ថ្ងៃខែ ឆ្នាំកំណើតមិនឲ្យភ្លេចឡើយ ។ ជារឿយៗ គាត់តែងសួរកូនឈ្មោះអ្វី? កើតឆ្នាំអ្វី? ខែអ្វី? ថ្ងៃអ្វី? ខ្ញុំកើតថ្ងៃអង្គារ ខែអស្សុជ ឆ្នាំខាល បើគិតឲ្យត្រូវពិតប្រាកដគឺ ថ្ងៃអង្គារទី ២៤ ខែ

តុលា ឆ្នាំ ១៩៥០ ។ ចំណែកនៅក្នុងបញ្ជីជាតិរបស់ខ្ញុំ ថ្ងៃខែកំណើតគឺ ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ១៩៥០ ឯនោះទេ ។

តាមទម្លាប់ ពួកយើងមិនដែលប្រារព្ធពិធីបុណ្យខួបកំណើតទេ ក៏ប៉ុន្តែ ឪពុកម្តាយខ្ញុំច្រើនរៀបចំពិធីសូត្រមន្តជាច្រើនដងក្នុងមួយឆ្នាំៗ ។ ឪពុកខ្ញុំឧស្សាហ៍អញ្ជើញហោរាឲ្យមកទស្សន៍ទាយ មើលជោគជតារាសីជាញឹកញាប់ ។ ហោរារបស់ឪពុកខ្ញុំឈ្មោះ តាឃី នៅភូមិព្រៃញ្ញៅ ។ តាឃី តែងតែគន់គូរវាយលេខអត្ថៈ តើរាសីរបស់គ្រួសារយើងឡើង ឬ ចុះ តើពេលណាដែលយើងត្រូវនិមន្តព្រះសង្ឃមកសូត្រមន្តស្រោចទឹក លើករាសី ឬ រំដោះគ្រោះ ។ តាឃី បានក្លាយទៅជាមនុស្សទុកចិត្តរបស់គ្រួសារយើង ហើយឪពុកម្តាយខ្ញុំក៏មានជំនឿលើគាត់យ៉ាងមុតមាំ ។ តាមការណែនាំរបស់គាត់ ឪពុកខ្ញុំតែងនិមន្តលោកតាវត្តរកាមកសូត្រមន្ត និង ស្រោចទឹករាល់ៗដង ជាទម្លាប់រៀងៗមក ។